**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**
**MINISTRY OF INFORMATION**
លេខ ៣២០ ព.ម សរាភ

ថ្ងៃពុធ ៣រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែមីនា ឆ្នាំ២០២០

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការតាមដានការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ខែកញ្ញាឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ខែមិថុនាឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨៩៥/០៣ ចុះថ្ងៃទី០១ខែកញ្ញាឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៣០អនក្រ.បក ចុះថ្ងៃទី០៥ខែសីហាឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ៣១អនក្រ.បក ចុះថ្ងៃទី១៣ខែកក្កដាឆ្នាំ២០០៣ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍នៃក្រសួងព័ត៌មាន
- យោងតាមតម្រូវការចាំបាច់។

## សម្រេច

**ប្រការ១.-**

បង្កើតគណៈកម្មការតាមដានការផ្សាយព័ត៌មានក្លែងក្លាយតាមប្រព័ន្ធផ្សព្វផ្សាយ និងតាមបណ្តាញទំនាក់ទំនងសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម អ៊ិក ប្រាថ្នា | រដ្ឋលេខាធិការប្រចាំការក្រសួងព័ត៌មាន | ប្រធាន |
| ២. ឯកឧត្តម ហួត ឃាងវេង | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម សុខ ប្រសិទ្ធិ | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤. ឯកឧត្តម ផុស សុវណ្ណ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកព័ត៌មាន និងសោតទស្សន៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. ឯកឧត្តម ជាច័ន្ទ បរិបូរណ៍ | រដ្ឋលេខាធិការ | សមាជិក |
| ៦. ឯកឧត្តម ជុំ កុសល | រដ្ឋលេខាធិការ | សមាជិក |

| | | |
|---|---|---|
| ៧. ឯកឧត្តម ស៊ូទី វង្សវិសិដ្ឋ | រដ្ឋលេខាធិការ | សមាជិក |
| ៨. ឯកឧត្តម អ៊ុក សំរេច | រដ្ឋលេខាធិការ | សមាជិក |
| ៩. ឯកឧត្តម ហ៊ីវ ជនទាថ | រដ្ឋលេខាធិការ | សមាជិក |
| ១០. ឯកឧត្តម មាស សុភ័ណ្ឌ | អនុរដ្ឋលេខាធិការ | សមាជិក |
| ១១. ឯកឧត្តម អ៊ុក គីមសេង | អនុរដ្ឋលេខាធិការ | សមាជិក |
| ១២. ឯកឧត្តមធឿនច័ន្ទលីនប៉ូឡែន | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៣. ឯកឧត្តម កៅ អ៊ឹមរ៉ែន | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៤. ឯកឧត្តម ឆាយ សុផល | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៥. ឯកឧត្តម លី ភិន់ហុង | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១៦. ឯកឧត្តម ឃឹម វុទ្ធី | អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា | សមាជិក |
| ១៧. លោកជំទាវឈឹមពៅសុកាន់នី | អគ្គនាយិកាវិទ្យុជាតិកម្ពុជា | សមាជិក |
| ១៨. លោកជំទាវ សុខ មុំនិមល | អគ្គនាយិកាទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP | សមាជិក |
| ១៩. ឯកឧត្តម តូច ណារត្ន | ទីប្រឹក្សា អគ្គនាយករងវិទ្យុជាតិកម្ពុជា | សមាជិក |
| ២០. ឯកឧត្តម ជួន ចាន់ការុណ | ទីប្រឹក្សា និងជាអគ្គនាយករង | សមាជិក |
| ២១. លោកជំទាវ ឆន ណារី | ទីប្រឹក្សា និងជាអគ្គនាយករង | សមាជិក |
| ២២.ឯកឧត្តម សាន ពុទ្ធារី | ទីប្រឹក្សា និងជាប្រធាននាយកដ្ឋាន | សមាជិក |

២៣. ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានមន្ទីរព័ត៌មានរាជធានី ខេត្ត សមាជិក

**ប្រការ៣._**

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- តាមដានការផ្សាយព័ត៌មានក្លែងក្លាយតាមប្រព័ន្ធផ្សព្វផ្សាយនានា និងដំណឹងមិនពិតតាមបណ្ដាញទំនាក់ទំនងសង្គម
- ធ្វើការឆ្លើយតបជូនសាធារណជនឱ្យបានទាន់ពេលវេលា តាមគ្រប់មធ្យោបាយដែលមានស្រាប់រាល់ការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ព័ត៌មានមិនពិត និងព័ត៌មាននាំឱ្យមានការជ្រួលច្របល់ក្នុងសង្គម
- សហការជាមួយស្ថាប័នសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ធ្វើការឆ្លើយតបឱ្យបានទាន់ពេលវេលារាល់ការផ្សព្វផ្សាយព័ត៌មានមិនពិតតាមគ្រប់មធ្យោបាយ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនិងអង្គភាព ឬក្រុមហ៊ុនបណ្ដាញទំនាក់ទំនងសង្គមដើម្បីរាំងខ្ទប់ (Block) គេហទំព័រ គណនី ឬទំព័រ (Page) ទាំងឡាយដែលផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ព័ត៌មានមិនពិត និងព័ត៌មាននាំឱ្យមានការជ្រួលច្របល់ក្នុងសង្គម និងចាត់វិធានការតាមផ្លូវច្បាប់
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងអំពីស្ថានភាពនៃការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ព័ត៌មានមិនពិត និងព័ត៌មាននាំឱ្យមានការជ្រួលច្របល់ក្នុងសង្គម និងស្នើសុំគោលការណ៍ដើម្បីអនុវត្ត និងចាត់វិធានការតាមនីតិវិធីច្បាប់ៗ

**ប្រការ៤._**

បង្កើតអនុគណៈកម្មការចំនួន២ ចំណុះឱ្យគណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម៖

**I. អនុគណៈកម្មការតាមដានមាតិកាផ្សាយ និងកំណត់អត្តសញ្ញាណ**

| | | |
|---|---|---|
| ១. ឯកឧត្តម ផូន ចាន់ការុណ | ទីប្រឹក្សា និងជាអគ្គនាយករង | ប្រធាន |
| ២. លោក ឈន វិបុល | ប្រធាននាយកដ្ឋាន ICT | អនុប្រធាន |
| ៣. ឯកឧត្តម ប្រាក់ វ៉ាន់ដា | ទីប្រឹក្សាក្រសួងព័ត៌មាន | អនុប្រធាន |
| ៤. ឯកឧត្តម សួង សុខេន | ទីប្រឹក្សាក្រសួងព័ត៌មាន | អនុប្រធាន |
| ៥. ឯកឧត្តម ស្វេះ ណាស៊ុ | ទីប្រឹក្សាក្រសួងព័ត៌មាន | អនុប្រធាន |
| ៦. ឯកឧត្តម ស៊ិន សត្ថា | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| ៧. លោកជំទាវ ឈឿន សុម៉ាលី | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| ៨. ឯកឧត្តម ខៀវ ណាវី | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| ៩. ឯកឧត្តម ហែម ប៊ុនធួយ | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| ១០. ឯកឧត្តម ព្រហ្ម ប៉ុណ្ណ | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| ១១. លោក វ៉ៃ គីមឡេង | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| ១២. លោក ឆន សុធា | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| ១៣. លោក ឡុង ភក្តី | ទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| ១៤. លោក យិន វាសនា | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៥. លោក ហិល សុការ៉ា | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៦. លោក អ៊ុង ចិន្តា | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៧. កញ្ញា ម៉ា បុប្ផា | ប្រធានការិយាល័យ | សមាជិក |
| ១៨. លោក ស្វេះ អាល់ហ៊ីន | ប្រធានការិយាល័យ | សមាជិក |
| ១៩. លោក សុវណ្ណ ពិទូរ្យ | អនុប្រធានការិយាល័យ | សមាជិក |

**អនុគណៈកម្មការនេះមានភារកិច្ចដូចតទៅ៖**

- តាមដានការផ្សាយព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយនានា និងបណ្ដាញទំនាក់ទំនងសង្គម ដែលជេរប្រមាថអង្គព្រះមហាក្សត្រ ថ្នាក់ដឹកនាំស្ថាប័នជាតិ និងរាល់ការផ្សព្វផ្សាយមិនពិត ព័ត៌មានក្លែងក្លាយញុះញង់បង្កឱ្យកើតមានការរើសអើងជាតិសាសន៍ ពណ៌សម្បុរ ជំនឿ សាសនា និងឬស្ថានភាពដទៃទៀតដែលច្បាប់ហាមឃាត់ ដែលអាចបង្កឱ្យកើតមានចលាចល ក្នុងសង្គម អន្តរាយដល់សន្តិសុខជាតិ ស្ថិរភាពនយោបាយ សណ្ដាប់ធ្នាប់សង្គម
- កំណត់អត្តសញ្ញាណគេហទំព័រ គណនី និងទំព័រ (Page) ប្រព័ន្ធផ្សព្វផ្សាយទាំងឡាយ ដែលផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ព័ត៌មានមិនពិត និងព័ត៌មាននាំឱ្យមានការជ្រួលច្របល់ ក្នុងសង្គម
- រាយការណ៍ និងផ្ដល់យោបល់ជូនគណៈកម្មការ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់។

**II. អនុគណៈកម្មការទំនាក់ទំនង និងចាត់វិធានការ**

| | | |
|---|---|---|
| ១. ឯកឧត្តម ផុស សុវណ្ណ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកព័ត៌មាន និងសោតទស្សន៍ | ប្រធាន |
| ២. លោកជំទាវ ឆន ណាវី | ទីប្រឹក្សា អគ្គនាយករង | អនុប្រធាន |
| ៣. ឯកឧត្តម សាន ពុទ្ធារី | ទីប្រឹក្សាប្រធាននាយកដ្ឋានសោតទស្សន៍ | អនុ.អចិន្ត្រៃយ៍ |

| | | |
|---|---|---|
| ៤. លោកជំទាវ ទីម សូលីណា | ទីប្រឹក្សា អគ្គនាយករង | សមាជិក |
| ៥. ឯកឧត្តម ហេង សង្ហា | ទីប្រឹក្សា អគ្គនាយករង | សមាជិក |
| ៦. លោក សូរ បូរី | អគ្គនាយករង | សមាជិក |
| ៧. ឯកឧត្តម ជា កែវចិន្តា | ទីប្រឹក្សា ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៨. ឯកឧត្តម យ៉ែម ណាយ | ទីប្រឹក្សា ប្រធាននាយកដ្ឋានមណ្ឌលព័ត៌មាន | សមាជិក |
| ៩. លោក អ៊ិន បញ្ញា | ប្រធានមន្ទីរអគ្គនាយកដ្ឋាន ព.ស.ទ | សមាជិក |
| ១០. លោកស្រី សុខ សេដ្ឋា | អនុប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១. លោក សូត លន់ | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១២. លោក សំ វិបុល | ប្រធានការិយាល័យ | សមាជិក |
| ១៣. លោក ឈិត ជីវ៉ែន | ប្រធានការិយាល័យ | សមាជិក |
| ១៤. លោក សុវណ្ណ វិចិត្រា | ប្រធានការិយាល័យ | សមាជិក |
| ១៥. លោក ទាន់ តារាជីវិន | អនុប្រធានការិយាល័យ | សមាជិក |
| ១៦. លោក ហ៊ាង តេកស្រេង | អនុប្រធានការិយាល័យ | សមាជិក |
| ១៧. លោក ស៊ិន វិសាល | មន្ត្រី | សមាជិក |

**អនុគណៈកម្មការនេះមានភារកិច្ចដូចតទៅ៖**

- សហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងស្ថាប័នគ្រប់គ្រងបណ្តាញទំនាក់ទំនងសង្គម ដើម្បីធ្វើការរាំងខ្ទប់ (Block) គេហទំព័រ គណនី ឬទំព័រ (Page) ទាំងឡាយដែលផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ព័ត៌មានមិនពិត និងព័ត៌មាននាំឱ្យមានការជ្រួលច្របល់ក្នុងសង្គម
- សិក្សា ផ្តល់យោបល់ និងស្នើសុំគោលការណ៍ពីគណៈកម្មការដើម្បីអនុវត្តការងាររបស់ខ្លួន និងរាយការណ៍ជាប្រចាំជូនប្រធានគណៈកម្មការអំពីលទ្ធផលការងារដែលបានអនុវត្ត។

**ប្រការ៥.** _

អនុគណៈកម្មការទាំងពីរមានសិទ្ធិជ្រើសរើសមន្ត្រីជំនាញបន្ថែមបង្កើតក្រុមការងារបច្ចេកទេសតាមតម្រូវការចាំបាច់ ដើម្បីអនុវត្តការងារបានទាន់សភាពការណ៍ និងមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៦.** _

នាយកខុទ្ទកាល័យក្រសួងព័ត៌មាន អគ្គនាយកដ្ឋានជំនាញចំណុះក្រសួងព័ត៌មាន និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

**បម្លងជូន៖**

- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ